ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្ត**
**បន្ទាយមានជ័យ**

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៦៨៥
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌ
លេខ:១២៣ (គ) /១០៧៥
ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាអសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសជាអសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យនាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ:៦៨៥ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ[redacted] វិន ភេទប្រុស អាយុ២៤ឆ្នាំ នីតិជន ជនជាតិខ្មែរ មុខរបរជាងភ្លើង ទីកន្លែងកំណើតភូមិសុវណ្ណសាគរ ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត[redacted] ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ, ឪពុកឈ្មោះ[redacted] (រ), ម្តាយឈ្មោះ [redacted] (រ),ប្រពន្ធឈ្មោះ[redacted]មានកូនចំនួន០២នាក់ កម្រិតវប្បធម៌ថ្នាក់ទី០៣ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារពីបទ លួច កាលពីអំឡុងឆ្នាំ២០១៤ (ខេត្តកំពត) ។

ដោយមានលោក[redacted] រិទ្ធី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៣៥០ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ។

ពីបទៈរំលោភសេពសន្ថវៈស្ថានទម្ងន់ទោស (ដោយមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ តាមមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ចុល ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាន [redacted] ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

ជនរងគ្រោះឈ្មោះ[redacted]ចិន្តា ភេទស្រី អាយុ១០ឆ្នាំ អាសយដ្ឋានភូមិក្បាលស្ពាន២ សង្កាត់

Scanned with CamScanner

ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ៨៨១ អ.យ.ង ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ៤១៣១ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូង ខេត្តបន្ទាយមានជ័យ ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ១០៣៥ ពស.ព្រជ "ក"/២០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ របស់ប្រធាន សាលាដំបូងខេត្តបន្ទាយមានជ័យ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ វេលាម៉ោង១៩និង០០នាទី នៅចំណុចភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានករណី រំលោភសេព សន្ថវៈ មួយកើតឡើងប្រព្រឹត្តដោយជនល្មើសឈ្មោ[redacted] វិន ភេទប្រុស អាយុ២៤ឆ្នាំ បានធ្វើសកម្មភាពចាប់រំលោភក្មេងស្រីឈ្មោះ[redacted] ចិន្តា ហៅអាទី ភេទស្រី អាយុ១០ឆ្នាំ ខណៈពេលដែលម្តាយក្មេងស្រីមិននៅផ្ទះ ដោយឃើញឱកាស ល្អជនល្មើសឈ្មោ[redacted]វិន ក៏បានចាប់ក្មេងស្រីឈ្មោ[redacted] ចិន្តា ហៅអាទី ស្រាតខោអាវអស់ និងឲ្យនាង [redacted] ហើយបានយកម្រាម[redacted]របស់នាង ក្រោយមកក៏បានយ[redacted]ឈ្មោះ[redacted] ចិន្តា ហៅអាទី ដែរ និងបានឲ្យកូនស្រីស្រាតខោអាវ និងយកដៃអង្អែល[redacted] ចិន្តា ហៅអាទី ដែរ និងបានយក[redacted]ហើយបានយក[redacted] ស្រីឈ្មោះឡា ចិន្តា ហៅអាទី បានប្រហែលមួយ [redacted] ក្រោយពីបានទទួលពាក្យបណ្តឹងពីម្តាយជនរងគ្រោះឈ្មោះ[redacted]ន ថុល ភេទស្រី អាយុ៤០ឆ្នាំ សមត្ថកិច្ចបានចុះស្រាវជ្រាវ និងឃាត់ខ្លួនជនល្មើសឈ្មោ[redacted] វិន មកកាន់អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ[redacted] វិន បានឆ្លើយថាៈកាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ខ្លួនកំពុងដេកមើលទូរសព្ទលើគ្រែដោយកូនស្រីចុងឈ្មោះ[redacted]ចិន្តា ហៅអាទី អាយុ១០ឆ្នាំ មកដេកនៅគ្រែជិតខ្លួន ពេលនោះប្រពន្ធខ្លួនទៅធ្វើការបាត់ គឺនៅតែខ្លួនពីនាក់កូនស្រី ក៏កើតអារម្មណ៍ផ្លូវភេទ ។បន្ទាប់មកខ្លួនបានឲ្យកូនស្រីឈ្មោ[redacted] ចិន្តា ហៅអាទីស្រាតខោអាវចេញអស់ និងឲ្យ[redacted] ខ្លួន ហើយខ្លួនបានយក[redacted] ។ ក្រោយមកខ្លួនបាន[redacted] ចិន្តា ហៅអាទី តែដាក់មិនចូល រួចខ្លួនក៏ឈប់ព្រោះខ្លាច ប្រពន្ធមកទាន់ ។បន្ទាប់មកទៀត បានប្រហែលជាបីថ្ងៃក្រោយខ្លួនបានឃើញ កូនស្រីចូលក្នុងបន្ទប់ទឹក ហើយខ្លួនក៏ចូលក្នុងបន្ទប់ទឹកជាមួយកូនស្រីឈ្មោះឡា ចិន្តា ហៅអាទី ដែរ និងបានឲ្យកូនស្រីស្រាតខោអាវឲ្យអស់ ហើយបានយ[redacted] ចិន្តា



Scanned with CamScanner

ហៅអាទី ខណៈពេលនោះខ្លួនមានអារម្មណ៍ចង់រួមភេទ រួចបានយក[redacted] ប្រដាប់ភេទនាងបានប្រហែលមួយភ្លែតក៏ដកចេញវិញ [redacted] ។លុះមកដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែលមួយរំលងអាធ្រាត ខ្លួនមានរឿងជាមួយអ្នកជិតខាងហើយខ្លួនខឹងខ្លាំងពេកក៏បានយកទូរសព្ទប្រពន្ធរបស់ខ្លួនបោកចោល ។ពេលនោះកូនស្រីរបស់ខ្លួនឈ្មោះឡា ចិន្តា ហៅអាទី ភ័យខ្លាំងពេកក៏បានប្រាប់ទៅប្រពន្ធខ្លួនថា ខ្លួនចាប់រំលោភនាង ទើបប្រពន្ធខ្លួនបានទៅប្តឹងសមត្ថកិច្ចឲ្យឃាត់ខ្លួនតែម្តង ។ សំណូមពរ សុំឲ្យតុលាការបន្ធូបន្ថយទោស ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ផុល បានឆ្លើយថាៈកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ កូនស្រីរបស់ខ្លួនឈ្មោ[redacted] ចិន្តា ហៅអាទីអាយុ១០ឆ្នាំបាននិយាយប្រាប់ខ្លួនថា ឈ្មោះ[redacted] វិន (ប្តីចុងរបស់ខ្លួន)បានឲ្យ[redacted]របស់គាត់ ហើយឈ្មោះ[redacted]វិន បានយក[redacted]រុក ចូលប្រដាប់ភេទរបស់កូនស្រីរបស់ខ្លួនឈ្មោះ[redacted] ចិន្តា ហៅអាទី ចំនួនពីរលើក ខណៈខ្លួនកំពុងទៅធ្វើការបាត់។លើកទី១ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោ[redacted] វិន បានហៅកូនស្រីខ្លួនឈ្មោះ [redacted]ចិន្តា ហៅអាទី ឲ្យឡើងទៅលើឡៅតឿក្នុងផ្ទះ ហើយឲ្យកូនស្រីខ្លួននាង[redacted]ទ និងបានយក[redacted]បស់កូនស្រីខ្លួនឈ្មោ[redacted] ចិន្តា ហៅអាទី ។លើកទី២ ពេលកូនស្រីរបស់ខ្លួនឈ្មោះឡា ចិន្តាហៅអាទី ចូលក្នុងបន្ទប់ទឹកឈ្មោះ[redacted] វិន ចូលទៅតាមហើយបានចាប់ដោះខោអាវកូនស្រីខ្លួនឈ្មោ[redacted] ចិន្តា ហៅអាទី និងបានយកប្រដ[redacted] ក្រោយពេលខ្លួនឮដូច្នេះក៏ទៅដាក់ពាក្យបណ្តឹងតែម្តង ។ សំណូមពរនៅក្នុងរឿងនេះខ្លួនមិនទាមទារសំណងទេ ។

ជនរងគ្រោះឈ្មោ[redacted] ចិន្តា ហៅអាទី បានឆ្លើយថាៈកាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ[redacted] វិន ដែលជាឪពុកចុងរបស់ខ្លួន បានឲ្យ[redacted]ស់គាត់ ហើយគាត់បានយក[redacted]ស់ខ្លួន ដោយខ្លាចម្តាយខ្លួនមកទាន់ក៏បញ្ឈប់សកម្មភាព ។ក្រោយមកខណៈពេលម្តាយខ្លួនមិននៅផ្ទះ ពេលខ្លួនចូលបន្ទប់ទឹកឈ្មោះ[redacted] វិន បានមក[redacted] ព្រមទាំងយ[redacted]ដាប់ភេទខ្លួន ពេលនោះខ្លួនឈឺប្រដាប់ភេទជាខ្លាំង។

តុលាការអានរបាយការណ៍លេខ១០២/២០កា.បជ.មកអ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ។

តំណាងអយ្យការសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ និងក្រោយពីបានស្តាប់តុលាការអានរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថាមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]វិន ភេទប្រុស ពីបទៈរំលោភសេពសន្ថវៈស្ថានទម្ងន់ទោស (ដោយមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ តាមមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារសិទ្ធិជនជាប់ចោទសន្និដ្ឋានថាៈក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ



Scanned with CamScanner

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ និងក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ឃើញថាកូនក្តីខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហើយនៅក្នុងពេលសវនាការនេះកូនក្តីរបស់ខ្លួនបានសារភាពនូវអំពើដែលខ្លួនបានប្រព្រឹត្ត ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យកស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់

## សំអាងហេតុ

១.កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ វេលាម៉ោង១៩និង០០នាទី នៅចំណុចភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានករណី រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសដោយមូលហេតុអាយុជនរងគ្រោះ) មួយកើតឡើងប្រព្រឹត្តដោយជនល្មើសឈ្មោះ [redacted]រិន ភេទប្រុស អាយុ២៤ឆ្នាំ បានធ្វើសកម្មភាពចាប់រំលោភក្មេងស្រីឈ្មោ[redacted] ចិន្តា ខណៈពេលដែលម្តាយក្មេងស្រីមិននៅផ្ទះ ដោយឃើញឱកាស ល្អជនល្មើសឈ្មោ[redacted] រិន ក៏បានចាប់ក្មេងស្រីឈ្មោះឡា ចិន្តា ស្រាតខោអាវអស់ និងឲ្យនាង [redacted] ហើយ[redacted] លេងប្រដាប់ភេទរបស់នាង ក្រោយមកក៏បានយក[redacted]ឈ្មោះ [redacted] ចិន្តា ដែរ និងបានឲ្យកូនស្រីស្រាតខោអាវ និងយក[redacted]ឈ្មោ[redacted] ចិន្តា ដែរ និងបានយកដៃរុកចូលប្រដាប់ភេទហើយបានយកប្រដាប់ភេទដាក់ពីលើប្រដាប់ភេទរបស់ក្មេងស្រីឈ្មោះ[redacted] ចិន្តា បានប្រហែលមួយ ភ្លែតក៏ដកចេញ ។

២.តាមចម្លើយជនជាប់ចោទឈ្មោ[redacted] រិន បានឆ្លើយថា:កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ខ្លួនកំពុងដេកមើលទូរសព្ទលើគ្រែដោយកូនស្រីចុងឈ្មោ[redacted] ចិន្តា ហៅអាទី អាយុ១០ឆ្នាំ មកដេកនៅគ្រែជិតខ្លួន ពេលនោះប្រពន្ធខ្លួនទៅធ្វើការ គឺនៅតែខ្លួនពីនាក់កូនស្រី ក៏កើតអារម្មណ៍ផ្លូវភេទ ។ បន្ទាប់មកខ្លួនបានឲ្យកូនស្រីឈ្មោ[redacted]ចិន្តា ហៅអាទីស្រាតខោអាវចេញអស់ និ[redacted]ខ្លួន ហើយខ្លួនបានយក[redacted] ។ ក្រោយមកខ្លួនបានយកប្រដ[redacted] ចិន្តា ហៅអាទី តែដាក់មិនចូល រួចខ្លួនក៏ឈប់ព្រោះខ្លាចប្រពន្ធមកទាន់ ។បន្ទាប់មកទៀត បានប្រហែលជាបីថ្ងៃក្រោយខ្លួនបានឃើញ កូនស្រីចូលក្នុងបន្ទប់ទឹក ហើយខ្លួនក៏ចូលក្នុងបន្ទប់ទឹកជាមួយកូនស្រីឈ្មោះឡា ចិន្តា ហៅអាទី ដែរ និងបានឲ្យកូនស្រីស្រាតខោអាវឲ្យអស់ ហើយ[redacted]ស្រីឈ្មោ[redacted]ចិន្តា ហៅអាទី ខណៈពេលនោះខ្លួនមានអារម្មណ៍ចង់រួមភេទ រួចបានយកប្រដាប់ភេទដាក់



Scanned with CamScanner

ពីលើ ប្រដាប់ភេទនាងបានប្រហែលមួយភ្លេតក៏ដកចេញវិញ ព្រោះខ្លាចកូនស្រីនាងឈឺ ។លុះមកដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោងប្រហែលមួយរំលងអាធ្រាត ខ្លួនមានរឿងជាមួយអ្នកផិតខាងហើយខ្លួន ខឹងខ្លាំងពេកក៏បានយកទូរសព្ទប្រពន្ធរបស់ខ្លួនបោកចោល ។ពេលនោះកូនស្រីរបស់ខ្លួនឈ្មោ[redacted]ចិន្តា ហៅអាទី ភ័យខ្លាំងពេកក៏បានប្រាប់ទៅប្រពន្ធខ្លួនថា ខ្លួនចាប់រំលោភនាង ទើបប្រពន្ធខ្លួនបានទៅប្តឹងសមត្ថកិច្ចឲ្យឃាត់ខ្លួនតែម្តង ។

៣.តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ថុល បានឆ្លើយថាៈកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ កូនស្រីរបស់ខ្លួនឈ្មោ[redacted] ចិន្តា ហៅអាទីអាយុ១០ឆ្នាំបាននិយាយប្រាប់ខ្លួនថា ឈ្មោ[redacted]ន (ប្តីចុងរបស់ខ្លួន)[redacted]របស់គាត់ ហើយឈ្មោ[redacted]រិន បានយក ប្រ[redacted] ចិន្តា ហៅអាទី ចំនួនពីរលើក ខណៈខ្លួនកំពុងទៅធ្វើការបាត់។លើកទី១ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ[redacted] រិន បានហៅកូនស្រីខ្លួនឈ្មោះ[redacted]ចិន្តា ហៅអាទី ឲ្យឡើងទៅលើឡៅតឿក្នុងផ្ទះ ហើយឲ្យកូនស្រី[redacted] ភេទ និងបានយកដៃរុកចូលប្រដាប់ភេទរបស់កូនស្រីខ្លួនឈ្មោះ[redacted] ចិន្តា ហៅអាទី ។លើកទី២ ពេលកូនស្រីរបស់ខ្លួនឈ្មោ[redacted]ចិន្តាហៅអាទី ចូលក្នុងបន្ទប់ទឹកឈ្មោះ[redacted] រិន ចូលទៅតាមហើយបានចាប់ដោះខោអាវកូនស្រីខ្លួនឈ្មោះ[redacted] ចិន្តា ហៅអាទី និងបានយក[redacted] ក្រោយពេលខ្លួនឮដូច្នេះក៏ទៅដាក់ពាក្យបណ្តឹងតែម្តង ។

៤.តាមចម្លើយជនរងគ្រោះឈ្មោ[redacted] ចិន្តា ហៅអាទី បានឆ្លើយថាៈកាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោ[redacted]ន ដែលជាឪពុកចុងរបស់ខ្លួន បានឲ្យ[redacted]របស់គាត់ ហើយគាត់បាន[redacted]ស់ខ្លួន ដោយខ្លាចម្តាយខ្លួនមកទាន់ ក៏បញ្ឈប់សកម្មភាព ។ ក្រោយមកខណៈពេលម្តាយខ្លួនមិននៅផ្ទះ ពេលខ្លួនចូលបន្ទប់ទឹកឈ្មោះ[redacted] រិន បានមកចាប់ស្រាតខោអាវអស់ រួចបានយក[redacted] ព្រមទាំង[redacted]ក្នុងប្រដាប់ភេទខ្លួន ពេលនោះខ្លួនឈឺប្រដាប់ភេទជាខ្លាំង។

៥.អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់រូបរាង្គកាយអ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសាធារណៈ ដែលច្បាប់ហាមឃាត់ ។

៦.មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]រិន ភេទប្រុស អាយុ២៤ឆ្នាំ ពីបទៈរំលោភសេពសន្ថវៈស្ថានទម្ងន់ទោស (ដោយមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ តាមមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

៧.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាម្តាយជនរងគ្រោះឈ្មោះ[redacted] ថុល បានចូលខ្លួននៅចៅក្រមស៊ើបសួរ និងនាពេលសវនាការ មិនបានទាមទារសំណងរដ្ឋប្បវេណី ។ តប្បីតុលាការមិនពិចារណាអំពីសំណង ។

៨.អយ្យការសន្និដ្ឋានថាៈ មានភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទ ស្នើសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។



Scanned with CamScanner

**ហេតុដូច្នេះសម្រេច**

១.ផ្តន្ទាទោសលើឈ្មោះ [redacted]ន ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ កំណត់ដាក់ពន្ធនាគាររយៈពេល **១០(ដប់)ឆ្នាំ** ពីបទៈរំលោភសេពសន្ថវៈស្ថានទម្ងន់ទោស (ដោយមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ តាមមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted], [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៧កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤

បន្ទាយមានជ័យ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner